# កម្មវិធីបង្វឹកក្រុមការងារបង្គោលអំណានយុវជន

## ខ្លាំងខ្លួនឯងថ្ងៃនេះ សម្រេចលទ្ធផលដោយចីរភាព

រៀបចំដោយ៖ លោក ឡាំ ឡាយ
ស្ថាបនិក និងអ្នកដឹកនាំអំណានយុវជន

### I. អំពីអំណានយុវជន (About AYN)

អំណានយុវជន គឺជាក្រុមការងារស្ម័គ្រចិត្តមួយដែលបង្កើតឡើងឆ្នាំ២០១៧ ក្នុងគោលបំណងផ្សព្វផ្សាយ ជំរុញ និងបណ្តុះបណ្តាលសមត្ថភាពអំណានទៅកាន់យុវជនខ្មែរក្នុងខេត្តចំនួន៣ គឺសៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ។

- ទស្សនវិស័យគឺជំរុញយុវជន ពីអ្នកអានធម្មតា ទៅជាអ្នកអានប្រកបដោយការត្រិះរិះពិចារណាបែបស៊ីជម្រៅ ពីអ្នកអានដែលមានការពិចារណាបែបស៊ីជម្រៅទៅជាអ្នកដឹកនាំដ៏មានសក្តានុពលម្នាក់នាពេលអនាគត។

  អំណានយុវជនជំរុញសកម្មភាពអំណាននៅជុំវិញរាជធានីខេត្តទៅកាន់យុវជនកម្ពុជាតាមរយៈការ៖
- ផ្តល់ជូននូវវេទិកាបណ្តុះបណ្តាលសមត្ថភាពរយៈពេល១២សប្តាហ៍
- ផ្តល់ជាសារសំឡេង ឬសំឡេងអំណានទៅកាន់យុវជនកម្ពុជា
- ផ្តល់ជាវេទិកាជំនួបអ្នកអាន និងអ្នកនិពន្ធ ចំនួន៩ខេត្តក្នុង១ឆ្នាំ
- ផ្តល់ជូនការស្រាវជ្រាវ និងការបណ្តុះបណ្តាលក្នុងវិស័យអំណាន
- រៀបចំជាវេទិការវាងអ្នកនិពន្ធ និងអ្នកអានដើម្បីផ្សព្វផ្សាយស្នាដៃថ្មីៗ

### II. ការពង្រឹងសមត្ថភាពក្រុមការងារបង្គោលក្នុងបរិបទកូវីដ-១៩ (Core Team Capacity Building During Covid-19)

#### ក-សង្ខេបអំពីគម្រោង Project Summaries

គម្រោងពង្រឹងក្រុមការងារបង្គោលក្នុងបរិបទកូវីដ-១៩ គឺជាដំណើរការនៃការបណ្តុះបណ្តាលក្រុមការងារអំណានយុវជនទាំងអស់ ដើម្បីទទួលបានចំណេះដឹងពាក់ព័ន្ធនឹងការដឹកនាំ ការបន្តវេនក្នុងវិស័យអំណាននាពេលអនាគតរបស់អំណានយុវជន។ គម្រោងនេះ នឹងបណ្តុះបណ្តាលក្រុមការងារគោលចំនួន១០រូប របស់អំណានយុវជន ឱ្យច្បាស់ការណ៍លើបច្ចេកទេសនៃការដឹកនាំ បច្ចេកទេសក្នុងការគ្រប់គ្រងចាត់ចែងក្រុមការងារ ឬការងារទៅតាមចំណាត់ថ្នាក់ ឬក៏ទៅតាមជំនាញរៀងៗខ្លួន និងអាចបណ្តុះបណ្តាល ព្រមទាំងចែករំលែកបន្តទៅកាន់ក្រុមការងារដទៃទៀតនាពេលអនាគត។

**ខ. គោលបំណងនៃគម្រោង Projects Purpose៖**

**ទី១ ពង្រឹងសមត្ថភាពក្រុមការងារបង្គោលដើម្បីបន្តវេន**
**ទី២ បង្កើតទំនាក់ទំនង និងចងក្រងជាបណ្តាញយុវជនក្នុងការអភិវឌ្ឍវិស័យអំណាននៅកម្ពុជា**

## ខ-អំពីវិធីសាស្ត្របណ្តុះបណ្តាល (Methodology)

ក្រុមការងារបណ្តុះបណ្តាលរបស់អំណានយុវជន នឹងប្រើប្រាស់វិធីសាស្រ្តបណ្តុះបណ្តាលមួយចំនួនដូចខាងក្រោម៖

1. **គ្រូមជ្ឈមណ្ឌល** មានន័យថារាល់មេរៀនដែលបង្រៀនចេញទៅ នឹងមានលក្ខណៈជាការពន្យល់ បទបង្ហាញរបស់អ្នកបណ្តុះបណ្តាល ដែលផ្អែកលើគោលបំណងនៃមេរៀនត្រឹមត្រូវ
2. **សិស្សមជ្ឈមណ្ឌល** មានន័យថា គ្រូបណ្តុះបណ្តាលនឹងប្រើប្រាស់វិធីសាស្រ្តត្រិះរិះពិចារណា ដោយការលើកយកករណីសិក្សាណាមួយដើម្បីឱ្យសិស្សធ្វើការវែកញែកពិភាក្សាគ្នាអំពីករណីសិក្សាមួយនោះ។ រាល់មេរៀននឹងមានការឆ្លុះបញ្ចាំងទៅកាន់សិក្ខាកាមដោយមានជាកិច្ចការបុគ្គល និងបទបង្ហាញរបស់សិក្ខាកាមម្នាក់ៗក្រោយពេលកិច្ចការរួចរាល់របស់សិក្ខាកាមនីមួយៗ។
3. **ការចងក្រងជាក្រុម** និងការអនុវត្តជាក់ស្តែងចំពោះការដឹកនាំអំឡុងពេលសិក្សាចប់។ អំណានយុវជន នឹងរៀបចំជាគម្រោងខ្លីៗណាមួយ ដើម្បីពង្រឹងសមត្ថភាពជាក់ស្តែងរបស់អ្នកចូលរួមដើម្បីសិក្សានិងវាយតម្លៃក្រោយវគ្គបណ្តុះបណ្តាល។

## គ-មេរៀនស្នូលសម្រាប់បណ្តុះបណ្តាល (Core Lessons)

១០ មេរៀននៃការបណ្តុះបណ្តាល ក្រុមការងារបង្គោលនឹងផ្តល់ចំណេះដឹងទៅកាន់អ្នកចូលរួមដូចជា៖

- យល់ដឹងកាន់តែច្បាស់អំពី ដំណើរការនៃការដឹកនាំ អំណានយុវជន ការចាត់ចែងធនធាន និងការសម្រេចលទ្ធផល
- មានចំណេះដឹងបច្ចេកទេសមូលដ្ឋានក្នុងការដឹកនាំ
- មានចំណេះដឹងផ្នែកដឹកនាំ និងគ្រប់គ្រងគម្រោងខ្លី
- មានមូលដ្ឋានគ្រឹះនៃការទំនាក់ទំនង និងការចេះធ្វើការងារជាក្រុម
- យល់ដឹងអំពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយបានត្រឹមត្រូវ

## ខ.សង្ខេបអំពីវគ្គបណ្តុះបណ្តាល និងការបង្រៀន (Contents & Course Outline)

ការបណ្តុះបណ្តាលនេះត្រូវបានចែកចេញជាពីរផ្នែកសំខាន់ៗគឺ ការអភិវឌ្ឍខ្លួន ដែលមានចំនួន ៤ប្រធានបទ ស្មើនឹង ៥-៨ម៉ោង និងផ្នែកទី២មានចំនួន៧ប្រធានបទស្មើនឹង១០-១៥ម៉ោង ហើយចំនួនប្រធានបទសរុបមានចំនួន១១ ស្មើនឹង ១៥-៩៥ ម៉ោង។ ការបណ្តុះបណ្តាលនឹងប្រើប្រាស់មធ្យោបាយបង្រៀនពីចម្ងាយរយៈកម្មវិធី Zoom។

| **ផ្នែកទី១** | **គោលបំណងនៃមេរៀន** | **ពេលវេលា** | **អ្នកបណ្តុះបណ្តាល** |
|---|---|---|---|
| ១.ណែនាំអំពី អំណានយុវជន | - យល់ដឹងអំពីការបង្កើតអំណានយុវជន ដំណើរការ គម្រោង វិធីសាស្ត្ររបស់អំណានយុវជន និងទស្សនវិស័យរបស់ អំណានយុវជន | ១:៤៥នាទី | |
| ២. វិធីសាស្ត្របង្កើតទម្លាប់ល្អ គ្រប់គ្រងទម្លាប់ល្អ និងចែករំលែកទម្លាប់ល្អ | - ការបង្កើតទម្លាប់ផ្ទាល់ខ្លួន<br>- ការចែករំលែកទម្លាប់ល្អរបស់ខ្លួនទៅកាន់អ្នកដទៃ<br>- ការចែករំលែកទម្លាប់របស់ខ្លួនទៅកាន់អ្នកដទៃ ក្រុមការងារ | ១:៤៥នាទី | |
| ៣.មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវ និងការបន្សាំខ្លួនជាមួយនឹងការរៀន | - យល់ដឹងអំពីមូលដ្ឋានគ្រឹះការស្រាវជ្រាវ និងដំណើរការរៀនសូត្រ<br>- វិធីសាស្ត្រនៃការបន្សាំខ្លួនរៀនសូត្ររឿងថ្មីៗ និងការផ្លាស់ប្តូរ | ១:៤៥នាទី | |
| ៤. មូលដ្ឋានគ្រឹះនៃភាពជាអ្នកដឹកនាំក្នុងខ្លួន | - យល់ដឹងអំពីភាពជាអ្នកដឹកនាំ អ្នកគ្រប់គ្រង និងអ្នកដើរតាម<br>- យល់ដឹងអំពីវិធីសាស្ត្រនៃការដឹកនាំខ្លួនឯង ការត្រៀមខ្លួនធ្វើជាអ្នកដឹកនាំ | ១:៤៥នាទី | |
| **ផ្នែកទី២** | | | |
| ៥. ការធ្វើកិច្ចការក្រុម និងទំនាក់ទំនង | - យល់ដឹងអំពីវិធីសាស្ត្រនៃការដឹកនាំក្រុម<br>- វិធីសាស្ត្រនៃការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព | ១:៤៥នាទី | |
| ៦. មូលដ្ឋានគ្រឹះ នៃការសរសេរអត្ថបទព័ត៌មាន | - មូលដ្ឋាននៃសរសេរអត្ថបទបែបព័ត៌មាន<br>- ការបំលែងការសរសេរធម្មតាទៅជាការសរសេរបែបព័ត៌មាន | ១:៤៥នាទី | |

| | | | |
|---|---|---|---|
| ៧. មូលដ្ឋានគ្រឹះនៃការរៀបចំវេទិកា និងកម្មវិធី | - យល់ដឹងអំពីការចាត់ចែងថវិកាផ្ទាល់ខ្លួន និងការបែងចែកថវិកាដើម្បីសន្សំនាពេលអនាគត | ១:៤៥នាទី | |
| ៨. មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងផ្នែករចនា Graphic Design | - ទទួលបានចំណេះដឹងនៃការរចនាផ្ទាំងផ្សព្វផ្សាយក្នុងកម្មវិធី Adobe Photoshop | ១:៤៥នាទី | |
| ៩. វិធីសាស្ត្រនៃការគ្រប់គ្រងផេក និងការប្រើប្រាស់ Hoot suite & Google Calendar សម្រាប់មាតិកាផ្សព្វផ្សាយ | - យល់ដឹងអំពីដំណើការនៃការគ្រប់គ្រងបណ្ដាញសង្គមរួមមាន Facebook និង Instagram<br>- ការរៀបចំកាលវិភាគផ្សាយ<br>- ការសរសេរមាតិកាសម្រាប់ផ្សាយ | ១:៤៥នាទី | |
| ១០. មូលដ្ឋានគ្រឹះនៃ Digital Marketing និងការប្រើប្រាស់ឧបករណ៍ឌីជីថល Zoom | - មូលដ្ឋានគ្រឹះផ្នែកទីផ្សារឌីជីថល<br>- របៀបដែលទីផ្សារឌីជីថលដំណើរការ<br>- របៀបនៃការប្រើប្រាស់កម្មវិធី Zoom និង Google meet សម្រាប់ទំនាក់ទំនង | ១:៤៥នាទី | |
| ១១. មូលដ្ឋានគ្រឹះនៃការថតរូបព្រឹត្តិការណ៍ | - យល់ដឹងអំពីការប្រើប្រាស់មុខងារសំខាន់ៗរបស់ Camera<br>- របៀបនៃការចាប់ប្លង់រូបភាព<br>- មូលដ្ឋានគ្រឹះនៃការរចនារូប ក្នុងកម្មវិធី Adobe Light room | ១:៤៥នាទី | |

បញ្ជាក់៖ ប្រធាន អាចនឹងមានការប្រែប្រួលទៅតាមស្ថានភាពចាំបាច់ណាមួយដើម្បីជាការប្រែប្រួល។ រាល់ការប្រែប្រួលផ្សេងដោយប្រការណាមួយ ក្រុមការងារនឹងជម្រាបជូនយ៉ាងហោចណាស់២ថ្ងៃមុន ដើម្បីជាការត្រៀមខ្លួន។

### ច.២សប្តាហ៍សាកល្បងដឹកនាំគម្រោង (2 Weeks Coaching)

ក្រុមការងារ នឹងបន្តគាំទ្រទៅកាន់អ្នកចូលរួមដូចជា៖

- ប្រឹក្សាយោបល់អំឡុងពេលនៃការដឹកនាំ ឬបំពេញក្នុងតួនាទីរបស់ខ្លួនណាមួយ
- ផ្តល់ធនធានបន្ថែមដើម្បីគាំទ្រ
- ផ្តល់ការបណ្តុះបណ្តាលបន្ថែម

## III. អ្នកទទួលផល (Beneficiaries)

### i. លក្ខខណ្ឌនៃការជ្រើសរើស (Criteria)

- ជាអតីតសមាជិក ឬអតីតក្រុមការងារ មានចំនួន១០នាក់
- ជាក្រុមការងារបច្ចុប្បន្ន (អាទិភាព)
- មានឆន្ទៈក្នុងការដឹកនាំ និងសិក្សាឈ្វេងយល់អំពីការជំរុញវប្បធម៌អំណាននៅកម្ពុជា
- មានពេលវេលាគ្រប់គ្រាន់សម្រាប់ចូលរួម

### ii. អត្ថប្រយោជន៍របស់អ្នកចូលរួម (Benefits)

- អ្នកចូលរួមនឹងទទួលបានប្រាក់ឧបត្ថម្ភ ៤០០០រៀល សម្រាប់មួយពេល
- យល់ដឹងកាន់តែច្បាស់អំពី ដំណើរការនៃការដឹកនាំ អំណានយុវជន ការចាត់ចែងធនធាន និងការសម្រេចលទ្ធផល
- មានចំណេះដឹងផ្នែកដឹកនាំ និងគ្រប់គ្រងគម្រោងខ្លី
- យល់កាន់តែច្បាស់អំពីភាពជាអ្នកដឹកនាំ និងវិធីសាស្រ្តនៃការធ្វើការងារជាក្រុម
- មានមូលដ្ឋានគ្រឹះនៃការទំនាក់ទំនង និងការចេះធ្វើការងារជាក្រុម
- យល់ដឹងអំពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយត្រឹមត្រូវ
- មានឱកាសក្នុងការដឹកនាំគម្រោងរបស់អំណានយុវជន
- ពង្រឹងសមត្ថភាពខ្លួនឯងតាមរយៈការងារសង្គម
- ទទួលបានវិញ្ញាបនបត្របញ្ជាក់អំពីភាពជោគជ័យនៃការចូលរួម

### iii. លក្ខណៈវិនិច្ឆ័យដែលបញ្ជាក់អំពីភាពជោគជ័យនៃវគ្គនេះ (Evaluations)

- ការចូលរួមក្រុមយ៉ាងសកម្មភាព
- មានវត្តមានគ្រប់ចំនួនដែលកម្មវិធីបានកំណត់
- គោរពតាមពេលវេលារាល់ពេលដែលមានការដាក់កិច្ចការក្រុមនានា
- អ្នកចូលរួមមាន ១០ពិន្ទុដូចៗគ្នាមុនពេលចូលរួម។ ប្រសិនជាអវត្តមាន ឬមានការអាក់ខានលើសពី៣ដង នៃ១០ដង នោះចាត់ទុកថា អ្នកចូលរួមពុំអាចសម្រេចជោគជ័យលើវគ្គបណ្តុះបណ្តាលនេះឡើយ។

## IV. គម្រោងកញ្ចប់ថវិកា (Budgeting)

| លេខ | មុខបញ្ជីចំណាយ | តម្លៃគិតជាមួយឯកតា | ចំនួន | ចំណាយសរុប | កំណត់ត្រា |
|---|---|---|---|---|---|
| | អ្នកបណ្តុះបណ្តាល | | | | |
| | ប្រាក់ឧបត្ថម្ភសម្រាប់អ្នកចូលរួម | | | | |
| | សម្ភារៈសម្រាប់បណ្តុះបណ្តាល | | | | |
| | ចំណាយរដ្ឋបាល និងផ្សេងៗ | | | | |
| | ការផ្សព្វផ្សាយ | | | | |
| | អ្នកគ្រប់គ្រងគម្រោង និងក្រុមការងារគម្រោង | | | | |
| | ចំណាយផ្សេងៗ | | | | |
| | សរុប | | | | |

## V. វិធីសាស្ត្រនៃការវាយតម្លៃ (Monitoring and Evaluations)

ក្រោយពីវគ្គបណ្តុះបណ្តាលក្រុមការងារអំណានយុវជន នឹងបង្កើតក្រុមគណៈកម្មការមួយដើម្បីធ្វើការវាយតម្លៃតាមរយៈទម្រង់វាយតម្លៃ Google Form អំពីគុណភាពនៃការបង្រៀន។ រាល់ការវិភាគ និងលទ្ធផលនៃការវាយតម្លៃអ្នកគ្រប់គ្រងគម្រោងនឹងធ្វើបទបង្ហាញទៅកាន់ក្រុមប្រឹក្សាភិបាលអំពីគុណភាព និងលក្ខណៈដែលអាចប្រើបានសម្រាប់វិធីសាស្ត្រនៃការបណ្តុះបណ្តាលក្រុមការងារបង្គោលនេះ។

## VI. សកម្មភាព និងកាលបរិច្ឆេទគម្រោង (Activities and Timeline)

# Project Schedule

| ACTIVITY | RESOURCE | TIMEFRAME – 2021 | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | October2021 | | | | November 2021 | | | | December2021 | | | | January 2022 | | | | February 2022 | | | | March 2022 | | | |
| | | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 | W1 | W2 | W3 | W4 |
| **ប្រែអង្គាស** | - តាម Internet និងតាមថ្នាក់ និងធ្វើជាបដា | | | | | | | | | | | | | | | | | | | | | | | | |
| **បង្កើត និងកៀងគរធនធាន** | -រៀបចំការផ្សព្វផ្សាយ<br>-រៀបចំកម្រងចុះឈ្មោះ កម្រងវាយតម្លៃ<br>-រៀបចំប្រព័ន្ធ Hupspot សម្រាប់គ្រប់គ្រងទិន្នន័យអ្នកចូលរួម<br>-ស្វែងរកអ្នកបណ្តុះបណ្តាល | | | | | | | | | | | | | | | | | | | | | | | | |
| តម្រង់ទិសផ្សព្វផ្សាយ ជ្រើសរើស និងសម្ភាសអ្នកចូលរួម | - ផ្សព្វផ្សាយតាមរយៈបទបង្ហាញទៅកាន់ក្រុមការងារ<br>- ជ្រើសរើសដំណាក់កាលទី ១<br>- ជ្រើសរើសដំណាក់កាលទី ២ | | | | | | | | | | | | | | | | | | | | | | | | |
| បណ្តុះបណ្តាល | ការបណ្តុះបណ្តាល មួយសប្តាហ៍២ពេល | | | | | | | | | | | | | | | | | | | | | | | | |
| វាយតម្លៃវគ្គបណ្តុះបណ្តាល | វាយតម្លៃ តាមរយៈកម្រងសំណួរវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | |
| **បិទវគ្គកម្មវិធី** | ចូលរួមពីតំណាងក្រុមកាងារអំណានយុវជន និងការប្រគល់វិញ្ញាបនបត្រ | | | | | | | | | | | | | | | | | | | | | | | | |

បញ្ជាក់៖ ពេលវេលានៃការរៀបចំនេះ អាចនឹងមានការប្រែប្រួលទៅតាមស្ថានភាពចាំបាច់ណាមួយដើម្បីជាការប្រែប្រួល។ រាល់ការប្រែប្រួលដោយប្រការណាមួយ ក្រុមការងារនឹងជម្រាបជូនយ៉ាងហោចណាស់២ថ្ងៃមុន ដើម្បីជាការត្រៀមខ្លួន។

## VII. ការរក្សាការសម្ងាត់ (Confidential)

រាល់ឯកសារទាំងអស់ និងព័ត៌មានទាំងអស់របស់ “អំណានយុវជន” ពុំអនុញ្ញាតយកទៅប្រើប្រាស់ក្នុងរូបភាពផ្ទុយក្រមសីលធម៌ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាឡើយ។ ប្រសិនជាមានករណីនៃការប្រើប្រាស់ក្នុងរូបភាពណាមួយចាំបាច់ គឺត្រូវមានការអនុញ្ញាតពីថ្នាក់ដឹកនាំរបស់អំណានយុវជនជាមុនសិន។




**លោក ឡាំ ឡាយ**

ស្ថាបនិក និងអ្នកដឹកនាំ

Email: fundraiseamnanyuveajun@gmail.com



## កសាងយុវជន តាមរយៈអំណាន

# អំណានយុវជន